**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៥៧៧ / ១៩ ក.ប/ស.ណ.ន ខ.ល

## សេចក្តីណែនាំ

## ស្តីពី

## ការបើកវិលើកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ជ្រាបថា ដើម្បីអនុវត្តប្រកាសលេខ៤៤៣ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងធានាភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ សូមលោក លោកស្រី ជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងត្រូវអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

### I - របៀបគិតអតីតភាពការងារ

- ប្រាក់បំណាច់អតីតភាពការងារអតិបរមា ដែលត្រូវបើកវិលើកមិនអាចលើសពី៦ខែនៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលស្មើនឹងចំនួន ១៥៦ថ្ងៃ។ មានន័យថាកម្មករនិយោជិតត្រូវទទួលបានប្រាក់វិលើកអតីតភាពការងារចាប់ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៨ គឺស្មើនឹងចំនួន ១៥៦ថ្ងៃ។
- ចាប់ពីឆ្នាំ២០០៨ រហូតដល់ ឆ្នាំ២០១៨ ចំពោះឆ្នាំការងារដំបូងដែលជាមូលដ្ឋានត្រូវវិលើកអតីតភាពការងារកម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារជាប់ជានិច្ចចាប់ពី ១ខែ ដល់ ៦ខែ ត្រូវទទួលបានប្រាក់បំណាច់អតីតភាពការងារស្មើនឹងចំនួន ៧,៥ថ្ងៃ និងបើបំពេញការងារបានលើសពី៦ខែ ត្រូវគិតស្មើនឹង ១ឆ្នាំពេញ ដោយត្រូវទទួលបានប្រាក់បំណាច់អតីតភាពការងារស្មើនឹងចំនួន១៥ថ្ងៃ (១៥ថ្ងៃក្នុង១ឆ្នាំ) ដូចតារាងខាងក្រោម៖

| អតីតភាពការងារ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | ចំនួនថ្ងៃសរុបសម្រាប់គិតវិលើកប្រាក់បំណាច់អតីតភាពការងារ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 11ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 6 | 156 |
| 10 ឆ្នាំ | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 150 |
| 9 ឆ្នាំ | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 135 |
| 8 ឆ្នាំ | | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 120 |
| 7 ឆ្នាំ | | | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 105 |
| 6 ឆ្នាំ | | | | | | 15 | 15 | 15 | 15 | 15 | 15 | 90 |
| 5 ឆ្នាំ | | | | | | | 15 | 15 | 15 | 15 | 15 | 75 |
| 4 ឆ្នាំ | | | | | | | | 15 | 15 | 15 | 15 | 60 |
| 3 ឆ្នាំ | | | | | | | | | 15 | 15 | 15 | 45 |
| 2 ឆ្នាំ | | | | | | | | | | 15 | 15 | 30 |
| 1 ឆ្នាំ | | | | | | | | | | | 15 | 15 |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៨ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

## II - របៀបគណនាប្រាក់រំលឹកអតីតភាពការងារ

ចំពោះកម្មករនិយោជិតទាំងឡាយណា ដែលបាននិងកំពុងបម្រើការងារតាំងពីមុនឆ្នាំ២០១៩ រហូតមក ហើយមានអតីតភាពការងារដូចក្នុងលក្ខខណ្ឌកំណត់នៅក្នុងចំណុច "I" ខាងលើ ការគណនាប្រាក់រំលឹកអតីតភាពការងារត្រូវអនុវត្តដូចខាងក្រោម៖

❖ ទី១ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ខែ

$$\text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង១ខែ} = \frac{\text{ផលបូកប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែ នៅក្នុងរយៈពេល ដែលត្រូវទទួលបានការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ}}{\text{ចំនួនខែសរុប ក្នុងរយៈពេលដែលត្រូវទទួលបាន ការរំលឹកប្រាក់បំណាច់អតីតភាពការងារ}}$$

❖ ទី២ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ថ្ងៃ

$$\text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ខែ}}{\text{២៦ថ្ងៃ}}$$

ដូច្នេះ ប្រាក់រំលឹកអតីតភាពការងារ ដែលត្រូវទទួលបានតាមឆ្នាំនីមួយៗ គឺ៖

$$\text{ប្រាក់រំលឹកអតីតភាពការងារក្នុង១ឆ្នាំ} = \text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ថ្ងៃ} \times \text{១៥}$$

**ឧទាហរណ៍៖** កម្មករនិយោជិតម្នាក់ចូលបម្រើការងារនៅរោងចក្រកាត់ដេរ ចាប់ពីដើមឆ្នាំ២០០៨ ដែលគិតមកដល់ឆ្នាំ២០១៨ គឺមានអតីតភាពការងារចំនួន ១១ឆ្នាំ ឬស្មើនឹង ១៣២ខែ។ នៅក្នុងឆ្នាំ២០០៨ គាត់ទទួលបានប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែចំនួន ៨០$។ ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៣ គាត់ទទួលបានប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែចំនួន ១០០$ និងចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ គាត់ទទួលបានប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែចំនួន ១៧០$។ ដូច្នេះ ការគណនាប្រាក់រំលឹកអតីតភាពការងារត្រូវអនុវត្តដូចតទៅ៖

❖ ទី១ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ខែ

- ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ខែ ស្មើនឹង ផលបូកប្រាក់ឈ្នួលសុទ្ធសាធ១៣២ខែ ចែកនឹង ១៣២ខែ (១១ឆ្នាំ x ១២ខែ)

$$\text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង១ខែ} = \frac{(\text{៨០\$x១២ខែ}) + (\text{១០០\$x១២ខែx៥ឆ្នាំ}) + (\text{១៧០\$x១២ខែx៥ឆ្នាំ})}{\text{១៣២ខែ}}$$

$$= \frac{\text{៩៦០\$} + \text{៦០០០\$} + \text{១០២០០\$}}{\text{១៣២ខែ}} = \text{១៣០\$/ខែ}$$

❖ ទី២ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង១ថ្ងៃ

- ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង១ថ្ងៃ ស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង១ខែ ចែកនឹង ២៦ថ្ងៃ

$$\text{ប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{១៣០\$}}{\text{២៦ថ្ងៃ}} = \text{៥\$/ ថ្ងៃ}$$

- ដូច្នេះ ប្រាក់រំលឹកអតីតភាពការងារ ដែលកម្មករនិយោជិតត្រូវទទួលបានតាមឆ្នាំនីមួយៗចាប់ពី ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ (១០ឆ្នាំ) គឺស្មើនឹង ១៥ថ្ងៃx៥$ x១០ឆ្នាំ=៧៥០$។ ក្នុងឆ្នាំ២០១៨ ទទួលបាន ៦ថ្ងៃx៥$=៣០$។

ក្នុងឧទាហរណ៍នេះ៖ កម្មករនិយោជិតត្រូវទទួលបានប្រាក់រំលឹកអតីតភាពការងារសរុបចំនួន ៧៨០$ (ដែលស្មើនឹង១៥៦ថ្ងៃ x ៥$)។

## III - របៀបបើករំលឹកប្រាក់បំណាច់អតីតភាពការងារ

- និយោជកត្រូវបើករំលឹកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត២ដងក្នុង១ឆ្នាំ ដែលក្នុងម្ដងៗស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមចំនួន ១៥ថ្ងៃ គឺចំនួន ១៥ថ្ងៃ នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងចំនួន ១៥ថ្ងៃទៀត នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែធ្នូ នៃឆ្នាំនីមួយៗ។ ការបើករំលឹកនេះ និយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិតទៅតាមអតីតភាពការងារជាក់ស្ដែងរបស់កម្មករនិយោជិតម្នាក់ៗ ពោលគឺចាប់ផ្ដើមពីឆ្នាំ២០០៨ រៀងមក។

- របៀបបើករំលឹកប្រាក់អតីតភាពការងារ ដែលមានមុនឆ្នាំ២០១៩ ត្រូវអនុវត្តដូចតារាងខាងក្រោម៖

| ប្រសិនមានអតីតភាពការងារ | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | ២០២៣ | | ២០២៤ | ចំនួនថ្ងៃសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | |
| 11ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 6 | 156 |
| 10 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | 150 |
| 9 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | | 135 |
| 8 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | | | 120 |
| 7 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | | | | | 105 |
| 6 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | | | | | | 90 |
| 5 ឆ្នាំ | 15 | 15 | 15 | 15 | 15 | | | | | | | 75 |
| 4 ឆ្នាំ | 15 | 15 | 15 | 15 | | | | | | | | 60 |
| 3 ឆ្នាំ | 15 | 15 | 15 | | | | | | | | | 45 |
| 2 ឆ្នាំ | 15 | 15 | | | | | | | | | | 30 |
| 1 ឆ្នាំ | 15 | | | | | | | | | | | 15 |

- និយោជកត្រូវញែកឱ្យដាច់ពីគ្នារវាងចំនួនប្រាក់ឈ្នួលប្រចាំខែ និងប្រាក់បំណាច់អតីតភាពការងារ ដើម្បីងាយស្រួលក្នុងការអនុវត្តកាតព្វកិច្ចពន្ធដារ។

## IV - ការផ្ដល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារតាមប្រភេទនៃកិច្ចសន្យាការងារ

១-បើកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ត្រូវបានប្រើប្រាស់លើសថិរវេលាដែលកំណត់ដោយច្បាប់គិតរហូតមកដល់ឆ្នាំ២០១៨ ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារត្រូវកំណត់ដូចខាងក្រោម៖

- ក្នុងករណីកម្មករនិយោជិតបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) តាមកាលកំណត់ម្ដងៗរួចហើយ កម្មករនិយោជិតមិនអាចទទួលបានប្រាក់បំណាច់អតីតភាពការងារទៀតទេ។
- ក្នុងករណីកម្មករនិយោជិតមិនបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) តាមកាលកំណត់ម្ដងៗនោះទេ និយោជកត្រូវផ្ដល់ប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត ដោយអនុវត្តតាម

ចំណុច "I", "II", និង "III" នៃសេចក្តីណែនាំនេះ។ អតីតភាពការងារត្រូវគិតតាំងពីថ្ងៃចុះកិច្ចសន្យាការងារដំបូង។

២-បើកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ត្រូវបានប្រែក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) ក្នុងឆ្នាំណាមួយ គិតរហូតមកដល់ឆ្នាំ២០១៨ ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារត្រូវកំណត់ដូចខាងក្រោម៖

- ក្នុងករណីកម្មករនិយោជិតបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) តាមកាលកំណត់ម្តងៗ ក្នុងអំឡុងពេលប្រើប្រាស់កិច្ចសន្យាការងារមានកំណត់ថិរវេលារួចហើយ និយោជកមានកាតព្វកិច្ចបើកផ្តល់តែប្រាក់រំលឹកអតីតភាពការងារ ដែលមិនទាន់បានបើក រហូតដល់ដាច់ឆ្នាំ២០១៨ប៉ុណ្ណោះ ពោលគឺ មិនតម្រូវឱ្យទូទាត់ពីពេលផ្តើមដំបូងនៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះឡើយ។
- ក្នុងករណីកម្មករនិយោជិតមិនដែលបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) តាមកាលកំណត់ម្តងៗនោះទេ និយោជកត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតដោយ អនុវត្តតាមចំណុច "I", "II" និង "III" នៃសេចក្តីណែនាំនេះពោលគឺ អតីតភាពការងារត្រូវគិតតាំងពីថ្ងៃចុះកិច្ចសន្យាការងារដំបូង។

## V - ការបញ្ឈប់កម្មករនិយោជិតពីការងារ

**ក**. ក្នុងករណីនិយោជកបញ្ឈប់កម្មករនិយោជិត ដោយគ្មានហេតុផលត្រឹមត្រូវ កម្មករនិយោជិតត្រូវទទួលបាន៖

១- ប្រាក់ឈ្នួលដែលមិនទាន់បានបើក។

២- ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមការកំណត់របស់ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

៣- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

៤- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន៧ថ្ងៃ បើកម្មករនិយោជិតនៅសល់អតីតភាពការងារ ចាប់ពី១ខែ ដល់ក្រោម៦ខែ។

៥- ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩សរុប ដែលនិយោជកមិនទាន់បានបើកផ្តល់។

ក្រៅពីចំណុចទី ១ដល់៤ ខាងលើ កម្មករនិយោជិតក៏អាចទាមទារសោហ៊ុយជំងឺចិត្ត ដែលស្មើនឹងប្រាក់បំណាច់អតីតភាពការងារ ដែលកម្មករនិយោជិតត្រូវទទួលបាន ប៉ុន្តែមិនត្រូវលើសពីប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំចំនួន ៦ខែនោះឡើយ។ ក្នុងករណីនេះ កម្មករនិយោជិតត្រូវបានរួចផុតពីកាតព្វកិច្ច ដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន។ ដោយឡែក និយោជកក៏មិនមានកាតព្វកិច្ចត្រូវតែទូទាត់តាមសំណើសុំរបស់កម្មករនិយោជិតនោះទេ។ ក្នុងករណីមិនមានការព្រមព្រៀង កម្មករនិយោជិតអាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

**ខ**. ក្នុងករណីនិយោជកបញ្ឈប់កម្មករនិយោជិតដោយកំហុសធ្ងន់ កម្មករនិយោជិតអាចទទួលបាន៖

១- ប្រាក់ឈ្នួលដែលមិនទាន់បានបើក។

២- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

## VI - គោលការណ៍រួម

១- អតីតភាពការងារកម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់អតីតភាពការងារ ត្រូវគិតចាប់ពីពេលបានចុះកិច្ចសន្យាការងារជាកម្មករនិយោជិតពេញសិទ្ធិ ដោយមិនរាប់បញ្ចូលថិរវេលាសាកល្បងទេ។

២- កម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន២១ថ្ងៃ ត្រូវចាត់ទុកថាបំពេញការងារបាន១ខែពេញ ដែលអាចទទួលបានប្រាក់បំណាច់អតីតភាពការងារ។

៣- ប្រាក់ឈ្នួលសុទ្ធសាធ ដែលយកមកធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់បំណាច់អតីតភាពការងារ ដែលមានមុនឆ្នាំ២០១៩ គឺជាប្រាក់ឈ្នួលសុទ្ធសាធដែលមិនគិតបញ្ចូលអត្ថប្រយោជន៍ផ្សេងៗ ជាអាទិ៍ ការកាលិកថែទាំសុខភាព ហានិភ័យការងារ និងប្រាក់ធ្វើការបន្ថែមម៉ោង។

៤- ចំពោះកម្មករនិយោជិត ដែលចូលនិវត្តន៍ឬទទួលមរណភាព ចាប់ពីឆ្នាំ២០១៩តរៀងមក និយោជកត្រូវបើកប្រាក់រំលឹកអតីតភាពការងារទាំងអស់ដែលនៅសល់ជូនកម្មករនិយោជិត ឬទាយាទនៃកម្មករនិយោជិតដែលបានទទួលមរណភាព។

៥- ថិរវេលានៃការឈប់សម្រាកលំហែមាតុភាព ការឈប់សម្រាកដោយជំងឺ និងគ្រោះថ្នាក់ការងារ ត្រូវរាប់បញ្ចូលជាអតីតភាពការងារដើម្បីគិតប្រាក់បំណាច់អតីតភាពការងារ។

៦- ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩នេះ ត្រូវបើកជាមួយនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលលើកទី២សម្រាប់ខែមិថុនា និងខែធ្នូ។ ដូច្នេះនៅពេលបើកប្រាក់ឈ្នួលលើកទី២សម្រាប់ខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗ កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលមានអតីតភាពការងារមុនឆ្នាំ២០១៩ ត្រូវទទួលបានប្រាក់ឈ្នួលលើកទី២សម្រាប់ខែមិថុនាឬខែធ្នូផង ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆមាសនីមួយៗចំនួន៧,៥ថ្ងៃផង និងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ផង ប្រសិនជាមាន។

៧- រាល់ការទូទាត់រំលឹកប្រាក់បំណាច់អតីតភាពការងារ និយោជកនិងកម្មករនិយោជិតត្រូវរក្សាទុកនូវឯកសារជាភស្តុតាង ដែលមានចុះហត្ថលេខា ឬស្នាមម្រាមដៃយល់ព្រមរបស់ភាគីទាំងពីរ ឬឯកសារដែលមានតម្លៃស្មើ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន អង្គភាពវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះបានត្រឹមត្រូវ និងធានាបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៨ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ *"ដើម្បីជូនជ្រាប"*

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

-សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

*"ដើម្បីអនុវត្ត"*

-ឯកសារ-កាលប្បវត្តិ